Champathong

# នាងចំប៉ាថោង ៨



22.082
T-K 151
(VIII)

កាលនោះបក្រី    ប្នមព្រះភូមី    សត្វស្វួតតគ្គង    និយុំនិយាយ

ប្រាប់ប្រាយដើមទង    ដូចដើមនោះហោង    មានមកហើយណា ៗ

ឯក្សត្រតាំងបី    សោតទូលអំពី    ដើមដែលដូចគ្នា

អស់អាចកិច្ចកាំ    ក្សត្រ៩អង្គា    ប្រាយប្រាប់ដោយនា

ដំណើរទីទ័យ ៗ    សុំស្និតស្នេហា    ព្រាហ្មព្រិទ្ធិអង្គអា

មាត្យមុខមន្ត្រី    បង្គំអភិវាទ    ក្រាបបាទក្សត្រី

ដោយអរពេកក្រៃ    ឥតឯគណនា ៗ    កាលនោះព្រះបាទ

សន្ទុះដនទាថ    នាំបីក្សត្រា    ឡើងលើប្រាសាទ

ស្អាងស្អាតសោភា    គួរគង់សុខសា    បាយបុណ្យពោធិ ៗ

ស្ដេចតែងឡើងទៅ    គាល់ព្រះចោមចៅ    ពីពង្សព៍ស

កាលនោះដេយ្យា    សុវណ្ណាស្រស់ស្រី    ឲ្យអស់មន្ត្រី

ពីការទេពព្រាក់ ៗ    ព្រះដៃធាធំ    ដែលនាងឧត្តម

ចូលចតសំណោក់    រៀបឧឡារិក    ពន្និកដៀងដាក់

សង្គុណអារក្ស    ព្រះដៃនោះណា ៗ    រួបស្រេចបរិបូណ៌

ក្សត្រថ្ងៃត្រកូល    ក្បានព្រះទេយ្យា    នីទុក្ខនីសោក

នីរោគភយា    ពស្ដេចផងនា ៗ    គ្រេមក្បានឥតហ្មង ៗ

សាស័ប្ទទិទាន    ស្មេះក្សេនពុំបាន    បាយបែងស្ងួសេង

យើងនឹងពណ៌នា យកក្បាទ្រើសឃ្លង ដោយនូវទំនង ដំណើរនេះណា ។

## បទព្រហ្មគីត

កាលក្សត្របីព្រះអង្គ ចាកចេញបោះបង់ឃ្លាតឃ្លា
ក្រោយនោះក្សត្រយក្ស ស្តេចទល់ទុក្ខទៀងក្រោយក្រែ ។
លង់លុះទើបព្រះបាទ ទ្រង់អាពាធកាលនោះនៃ
ឈឺឈៀប ៗ ល្ហិតល្ហៃ ល្អិតល្អន់អស់ព្រះឥន្ទ្រិ ។
ទោះបីពេទ្យមេមុត ដែលធុត ៗ មកមើលក្តី
មិនមានស្រាកស្រានពី ព្រះរោគ្គឥតឯស្រយាល ។
ស្តេចទ្ងួញទៅរាជបុត្រ ថ្ងៃវិសុទ្ធនូវកុមារ
ឱស្ងួនសាច់សង្ក្រា ទាំងបីបង់បាត់ទៅទៅ ។
ឪពុកឈឺទ្ងន់ ទុកពន់ពេកណាពៅ
ម្ចះសុំពុំបាននូវ យល់មុខមាសរតស្នេហា ។
ទបើម្តេចនឹងស្លាប់ លែងមានក៏ពមានស្ងួនក្យ
មូលមួយនូវអាយរ បានឪពុកនឹងផ្តែផ្តាំ ។
ផ្ញើខ្លោចអង្គអាត្មា នេះលើបាឲ្យថែទាំ
សង្ខារតាមដោយកម្ម នឹងចៀសចាកពុំបានឡើយ ។
មួយសោតរាជសម្បត្តិ ស្វេតឆត្រផងជាត្រើយ

បើអញស្លាប់ទៅហើយ    តើនណាទីងគ្រប់គ្រង ៗ
ទុកូនកែវពន្លក    សួន្ទើយមកឆាប់នេះម្តង
សោះឪពុកតែងរង់    ទុក្ខទន្ទឹងពេកក្តាត់ណា ៗ
ស្តេចទ្ងូញទៅពោធី    សត្វវរិសេសសោភា
ព្រះជម្ងឺពៀបពា    ពន់ពុំស្បើយជាឡើយនៃ ៗ

## បទកាកគតិ

យើងនូវដំណាល    ដៃដេតកូបាល    នូវនាងនាថថ្លៃ
ស្តែងស្តេចគូគង់    លុះលង់យូរក្រៃ    ក្ងក់ព្រះហឫទ័យ
ទៅក្រុងយក្សា ៗ    ថាទុះយើងឃ្លាត    ចាកចោលព្រះធាទ
ក្សត្រយក្សថ្លៃថ្លា    ឆ្នាំបីទៀងទាត់    សំក្សត្រសោភា
ទន្ទឹងយើងជា    កូនកាលនេះម្តង ៗ    មួយក្សត្រសោភ័ណ
ស្តេចទូវហេមន្ត    នាយនោះក្តីហោង    សំទឹងទន្ទឹង
ខេខឹងកន្ទុង    ថាយើងតាំងសង់    ចោលពុំនាំពា ៗ
គួរតែយើងទៅ    សួរព្រះចោមចៅ    តាំងបីអគ្គា
ទោះសានទោះសុខ    ទោះយប់យាមា    ទោះថ្ងឹងទោះថ្មា
មានតែយើងហោង ៗ    ក្សត្រីក្សត្រា    ព្រមព្រះបិន្តា
មូលមួយឥតហ្ទង    ក្សិនក្សត្រតាំងបី    ស្តេចលីលាផ្គង

គាល់ព្រះប្យះប្យង  មាតាបិតា ៗ  ស្ដេចទិនអង្គអ
កិពទគោរព  ប្រណាម្យទូលថា  បពិតយើងខ្ញុំ
នូវសូមក្រាបលា  វិលត្ថានគាព  នគរនាយនៃ ៗ
វៃក្រង់ក្រុងយក្សា  នូវក្សត្រទេវហា  ស្ដេចទន្ទឹងក្រៃ
ហេតុនេះខ្ញុំលា  យាត្រាវិលវៃ  ហាក់ខ្ញុំដោះដៃ
ចោលក្សត្រឯកាយ ៗ  ជីនុកជីនី  ស្ដេចស្ដាប់សំដី
បុត្រតពន្រាយ  ព្រះទិស្ឋថ្លែងថា  ទុប្បាស្សនើយ
អញទុំពុកម្ដាយ  សព្វថ្ងៃមានប្បា ៗ  បើស្វនទៅហើយ
យើងនូវថ្វីឡើយ  គ្រមោចកំព្រា  មួយក្សត្រយក្សយស
គុណក្រាស់ក្រថា  យើងទៅទាំងប្បា  បង្គួយក្សយង់ ៗ
ក្សត្រ៥អង្គា  ព្រមព្រះបិត្តា  ក្សិនក្សត្រពុំលង់
ឲ្យអស់សេនា  យោធាពលពង្ស  កេត្រាផ្ចិតផ្ចង់
ស្ដេចត្រេបផលសា ៗ  រៀបរួចស្រាប់ស្រេច  ទើបទូលសម្ដេច
ព្រះបរមពជា  កាលនោះព្រះបាទ  ននាថវៃថ្លថា
ចចុះគេត្រា  ទាំង៥អង្គនៃ ៗ  សំពៅមួយពាន់
ប្រាំរយណែនណាន់  ទាំងរាជផលសៃ  ផងក្ដោងប្រែងប្រាង
ស្រាង់ស្រាង់ប្រិនក្រៃ  ពលផងទីទៃ  បុះដិះគ្រប់គ្នា ៗ

ទាំងគិលៀងក្សត្រ    សឹងចចុះថ្វាត់  គង់លើគេត្រា  លង់លុះល្មមពា
វេលាធាយា    ស្រេចស្រាយយុត្តា  ហើយហូតស្វាបក្ដោង

## បទភុជង្គ

លិបពៀបលន្ទាបចេញផ្គង    ប្រើនក្រៃព្រាតព្រោង
លឿនលន់សោះសា ៗ    ព្រះពាយផ្សប់ផ្សាយវាតា
គុនទៅគង្គា    លន្ទិមបាត់ត្រើយ ៗ
គួរខ្លាចពុំអាចធ្ងន់ឡើយ    ខ្ទះមៀនមើលហើយ
ភិតភ័យតក្កមា ៗ    វេលកបក់បោកគេត្រា
ធំ ៗ ក្ដាត់ណា    ប៉ុន ៗ ភ្នំនៃ ៗ
ខ្ទះស្គាត់ប្រយត្នពេកក្រៃ    ទ្រង់ត្រិះរិះសែ
ដម្រង់សំពៅ ៗ    ប្រួតកោះផ្ទុកផ្ទោះទៀងទៅ
ហោមន្តឥតសៅ    បុរីផ្កា ៗ
បើកផ្ទុមលឿនត្រឹមទឹងគ្នា    មើលថ្មសិលា
ជ្រោយកោះខ្សាច់ខ្សាយ ៗ    ក្សត្រាសេនារុះរាយ
ក្រសាលសប្បាយ    ដោយដងដលសា ៗ
សត្វទឹកពន្ទឹកមហិមា    មេធោមេផា
ប្រើនក្រៃពន់ពេក ៗ    ពុំស្គាល់ដោយពណ៌បំឡែក

អានទ្នអានែកក្រនឹងគណនា ៗ ដោយព្រានមានថ្មសិលា
ថ្មភ្នឹនៅផ្កា មហាក្រហម ៗ
ផ្កាថ្មស្រម៉ស្រយម មហាហង្សផុះអម
នូវនិលពីសី ៗ ពពុះទឹកផុះអំពី
ទឹកប្រៃនោះក្ដី ល្អល្អះសសុត ៗ
ព្រោងព្រាតអណ្ដាតស្រមុទ្រ ថ្មដាថ្មផុត
កំពោក្ដីណា ៗ មានរូងកន្ទុងឈូងបុព្វតា
រាំងនុកបកក្រ ចូលកាប់សម្បុក ៗ
ខ្វាខ្យល់ទ្រុសទ្រៀវគគុក ខៀវខាន់សេតសុខ
ស្រែកករកគូ ៗ ផ្កាថ្មសឹងល្អសោភា
ហាក់ជាងរចនា រន្ទាប់ផ្គូផ្គង ៗ
ខ្វះសេតខ្វះសអន្ទង ខ្វះខ្មៅបៃតង
ខៀវខាន់ពណ៌ត្នា ៗ មានថ្មផុនមុនត្រៀបត្រា
ថ្មក្ដារខៀនណា ថ្មសាកះសាតនៃ ៗ
ថ្មពេជ្រលាយលេបថ្មដៃ រគៀបល្អក្រៃ
ថ្មប្រាក់ថ្មមាស ៗ សាភាយផុះលាយដេរដាស់
រៀងពល់ពោពាស ច្រើនក្រៃលើសលន់ ៗ

លំលាយសាពយដីប៉ុន　　ដើងមាន់ហាយហុន

ឆ្កុកឆ្កាស់លើគ្នា ៗ　　គ្រាំក្រែងចាក់ប្រែងលៀសណា

គ្រំជំពុសទា　　ចាបចៀបគីរុំ ៗ

ប្រប់កោះខ្យងដោះក្រមុំ　　ខ្យងប្រម៉ោយដុំ

រីខ្យងសសេះ ៗ　　មានងាវផាតជងគ្រាំសេះ

ខ្យងដែកបាបេះ　　ចាបសៀវដោយប្រាំង ៗ

ខ្យងក្តក់ខ្យងមុខខ្យងសាំង　　ខ្យងប្រតិកតាំង

ខ្យងសោកច័កបន្ទ ៗ　　ខ្យងហៀនខ្យងចិញ្ចៀនដាន់

ប្រើនពាន់ណាស់ណាន់　　កង្កពដលសែ ៗ

គុនឯសត្វមេបំប្រែ　　ក្របកនាងនៃ

គ្រំកបិតស្វា ៗ　　ព្រះបាទនាថថ្ងៃថ្វា

ទតហើយក្សត្រា　　ប្រាយប្រាប់ប្អូនស្រី ៗ

សរសើងំណើផលធី　　មើលមានគីរី

កណ្តាលគង្គា ៗ　　ជ្រោយជ្រោះកៀនកោះសិឡា

ពង់ពស់សោះសា　　ស្រឡូងជ្រាលជ្រៅ ៗ

បើកស្រូតរើរូតសំដៅ　　កន្ទុះខៃទៅ

ដួលពាមហើយណា ៗ　　បើកចូលព្រាមមូលគេត្រា

ទាំងរយនឹងហា សិបសោកជាម្ដង ៗ
ដល់ជាក់ដាក់ស្ងាបក្ដាន់ផង បតរៀងដោយដង
ហើយបោះយុតប្កា ៗ សាទរត្រេកអរគ្រប់គ្នា
វិកពយកក្រ្ដា ដង្វិតបានដល់ស្រុក ៗ
ក្អាកក្អាយសប្បាយឥតទុក្ខ នឹងបានយល់មុខ អស់ញាតិសន្ដាន

## បទកាក

ក្សត្រ ៤ ព្រះអង្គ កាលដល់កំពង់ អស់រាស្ត្រប្រជា
ផ្អួកផ្អើលរដៅ ឆោឡោមហិមា មកមើលគេត្រា
ស្មើផ្អួកសោតហោង ៗ យល់ផ្ទេកគួរឆ្ងល់ សំពៅមកដល់
ច្រើនក្រៃគន្ទង ខ្វះមើលយល់កូន យល់ប្អូនយល់បង
អរឯងអើងកង ស្រែកស្នូរពីឆ្ងាយ ៗ ខ្វះបាសចុះទៅ
ក្រឡេកឃើញចៅ ជាមេមាសយាយ អ្នកទៅយូរលង់
បោះបង់ឃើងអាយ សួនទើយសប្បាយ ជាទេបុត្រី ៗ
ឯអ្នកគេត្រា យល់ជូនយល់តា ដន្ទឹងបោះខ្ចី
ដ្រៀតដ្រែកដោយចង់ ឆ្ងើយឆ្ងល់សំដី សំពៅដល់ដី
សួរញាតិកា ៗ ដីឃើញប្រពន្ធ ឪនទិបអរលន់
និយាយការទ់គ្នា កូនបានយល់មុខ ឪពុកអាត្មា

អរង្គមហិមា ត្រូវត់ទទួល ៗ ប្រពន្ធឃើញប្តី
អរង្គឥតបី សំណោះស្រោកស្រួល ដោយក្តីស្នេហា
ចរចា សាកសួរ រួសរាយទទួល ទុំនែកស្រោចាយ ៗ
កាលនោះព្រះបាទ ធម្មិកនរាជ នូវនាងពន្រោយ
ស្តេចជ្រាបប្រាកដ ជាបុត្រនោមឆាយ នូវព្រះន្រោយ
ធិបេសជនគោ ៗ ស្តេចដល់កំពង់ ហើយទើបព្រះអង្គ
ឭយការឭយគោ ឲ្យរៀបរាជយាន ប្រើងថានឧត្តមោ
ទៅទទួលពោ ធិសក្តិថ្ងៃថ្វា ៗ នូវអង្គព្រះបាទ
ដៃដេតនរាជ នាងសុវណ្ណា ឯក្សត្រទាំង៥
ឲ្យនាំអាជ្ញា ទៅទួលក្សត្រា ធម្មិកភូធរ ៗ
ដ្បិតព្រះរាជបុត្រ ពិសេសពិសុទ្ធ • នត្តោបវរ
ឥឡូវស្តេចដល់ មណ្ឌលព្រះនគរ មកទាំងភូធរ
សទុភជា ៗ ទាំងនាងកេសណី ព្រះអគ្គមហេសី
មូលមកទីងគ្នា ដល់ដើងកំពង់ ហើយចង់យាត្រា
មកថ្វាយវន្ទា សូមជ្រាបនេះម្តង ៗ សេនានាំដល់
ជ្រាបហើយទោះពល បើកបន្ទូលស្នង ជាអញអរក្តាត់
ទីងក្សត្រជន្មូង អរមួយសោតហោង ក្សត្រ ៣ អង្គា ៗ

បានមូលមកដល់ | បបួរជួបគល | បំណាងប្រាថ្នា
ឲ្យអញ្ជើញក្សត្រ | ឆាប់ថ្វាត់ម្នីម្នា | ដ្បិតយើងទុក្ខា
ទទួលសព្វថ្ងៃ ៗ | រីឯសេនា | នាំយានយាត្រា
ជួបដល់ហើយនៃ | ទើបទូលព្រះបាទ | ននាថជៀសដៃ
ព្រះបីតាថ្លៃ | ឲ្យអញ្ជើញហោង ៗ | ទើបឯសេនា
ដែលនាំគាថា | វិលវឹងមកផ្គង | ទូលក្សត្រទាំង៤
គិប្ដូកាពាក្យផង | សព្វគ្រប់ផ្ដាំម្ដង | ដូចស្ដេចផ្ដាំថា ៗ
ក្សត្រ៤ព្រះអង្គ | ជ្រាបហើយពុំលង់ | គង់យានយាត្រា
លុះដល់ប្រាសាទ | ព្រះបាទពកផា | ឡើងលើត្រឡា
គិនាល់ពេនរត ៗ | ឯតីកផា | អរឱបប្រាក
ព្រះពោធិសត្វ | នូវព្រះរាជបុត្រ | ពីសមុទ្របារត
បន្ទូលទៅព្រាត់ | ទឹងស្ដេចដូង ៗ | ពេះភាយបរបា
ទៅមកកាន់គ្នា | ប្រាយប្រាប់ដើមទង | សួរសព្វពុំខុះ
កន្ទះឡើយហោង | ស្នេហាគួបចង | មេត្រីនឹងគ្នា ៗ
យើងនៅដំណែន | ដំណាលចាយចែង | ដំណើរយកក្រ
ស្ដេចទ្រង់អាពាធ | សល់ខ្នាតវិធផា | ទុរន្តមហិមា
ទឹងសព្វមួយផង ៗ | ខំមានបន្ទូល | សំណោះមធុរ៖

ទូវសេនាផង ឲ្យចំលើលា យាត្រាទៅគួង
ទូលបុត្រស្ងួនត្រង់ ឲ្យមកម្ចីមា ៗ ផ្សែតផម្ចីខ្ចាង
ផ្ទួសផ្ទួកាន់កំាង ហៀបក្បែរផ្ទា បើយូរពុំផល់
ផ្ចូបកលាបា ប្រាងឡើយស្ងួនក្ស ទាន់ផង្ហើមឡើយ ៗ

## បទពំនោល

កាលនោះពាំសមេឃយក្សធ្វើយ ថាខ្ញុំឯងហើយ
ទឹងទៅអញ្ជើញក្សត្រា ៗ ទឹងត្រឡាប់មកដូចថា
ថ្ងៃនេះឯងណា ដល់ដូចព្រះរាជហឫទ័យ ៗ
ស្រេចយក្ខក្រាបលាវិលវៃ ហិចហោះប្រៀវប្រៃ
ស្វាញស្ទុះហាក់ក្សត្រោមា ៗ សន្ទឹកបីគគិកសោះសា
ព្រៃព្រឹក្សលតា រលំរលាយរាបទៅ
ផ្ដោយតេជៈយក្ខយង់ឃោឃៅ រំពេជក្សិនទៅ
ដល់ដូចព្រះរាជអាជ្ញា ៗ យក្ខកកាយវិវន្ទា
ប្រណម្យទូលថា បពិតសម្ដេចចក្រី ៗ
ពីព្រះបីតាភូមី ប្រើខ្ញុំមកនី
ក្រាបទូលឲ្យជ្រាបបិត្តា ៗ ផ្សិតព្រះផ្ដិនុកថ្ងៃថ្វា
ស្ដេចទ្រង់ព្រះអា ពាធកាលពីក្រោយស្ដេចមក

ល្ហិតល្ហៃល្ហិនល្ហៃសេរក នគោពទូក
នូវពីព្រះអង្គបុត្តា ៗ ឥឡូវយូរយល់រឺជា
រៀបពន្ធកាត់ណា ឲ្យមកអះញ្ជើញចោមចៅ ៗ
កុំស្ដេចផ្សូផ្សងលង់នៅ យូរហើយក្រែងទៅ
ពុំទាន់ដង្ហើមបិតា ៗ ក្សិនក្សត្រប្រាំពីរអង្គា
ស្ដាប់ពាក្យយក្សា ស្ដេចកិតឯងឥតស្មារតី ៗ
ទ្រង់ព្រះកន្សែងសែនថ្វី ស្រេបទើបភូមី
ព្រះបុរទៃដេតកផា ៗ នូវនាងនាថសុវណ្ណា
ទូលទៅបិតា មាតានាំង ៤ ព្រះអង្គ ៗ
ខ្ញុំសូមលាតណាគ្រេបគ្រង់ នាំបុត្រវរវង្ស
ទៅឋានក្សត្រកន្យាយក្សា ៗ កាលនោះទើប ៤ ក្សត្រា
បើកបន្ទូលថា ហៃស្ងួនសំឡាញ់ស្នេស្នង ៗ
បើបាយាត្រាទៅផ្គង យើងសោកទៅផង
ឲ្យទាន់ដង្ហើមយក្សា ៗ បំណាប់ព្រះគុណករុណា
ទុកលើសិរសា ពុំដាច់ដល់តិចឡើយហោង ៗ
ឥឡូវយើងនូវសូមសង គុណព្រះបង្រះបង្ស
ពិសេសសពិប្ដូរសោកា ៗ ក្សត្រប្រាំពីព្រះអង្គា

ព្រមព្រះបិតា ហើយត្រាស់ឲ្យអស់មន្ត្រី ៗ
ប្រុងប្រៀបរុសរៀបឆាប់ខ្ចី ដ្បិតព្រះចក្រី
នឹងត្រេចពុំលង់ឡើយណា ៗ ក្បិននោះពាសមេឃយក្សា
ប្រណម្យទូលថា សូមទានកុំព្រួយព្រះទ័យ ៗ
កុំស្តេចទឹងយកយាននៃ ខ្ញុំនាំក្សត្រថ្ងៃ
ហិចហោះផ្ទុកផ្ទោះយាត្រា ៗ រំពេចដល់ដូចទេយ្យា
យូរហើយបីគា ស្តេចរិងទទឹងពេកក្រៃ ៗ
ក្សត្រប្រាំពីរអង្គនោះនៃ ព្រមព្រះហឫទ័យ
ទឹងត្រេចដោយដងវេហាស ៗ ក្បិននោះពាសមេឃយក្សា
លាតលាហត្ថា ឲ្យក្សត្រប្រាំពីរឡើងគង់ ៗ
សួយសុះផ្ទុកផ្ទោះពុំលង់ ស្រេចបានដល់ក្រុង
គាភបុរីយក្ខយស ៗ ដល់ដាក់ព្រះពង្សត្រូទូស
នូវក្សត្រទាំងអស់ ប្រាំពីព្រះអង្គនោះណា ៗ

## បទកាក

ស្តេចបរបូលថ្កាន ទៅដល់ក្សត្របាន យល់ក្រុងយក្សា
ទុនទុបព្រះបាទ អភិភពទសោភា ហាក់ដូចផន្ទា
ស្លាប់មុនហើយហោង ៗ ឯក្សត្រយក្សា ទំបែរប្រែប្រា

ចបបុត្រស្នេស្នង នូវព្រះជនគោ សេដ្ឋប្រះប្រង
អង់ឯលបោសខ្នង បន្ទូលត្រាស់ថា ៗ ចិស្ទូនវិលក្ខ
កម្មពីអតីត: តាមទាន់ហើយណា
ចពុំបានទៅ យល់ពៅពុំងា ទាំងបីអគ្គា
ដូចមុនឡើយហោង ៗ ចឆ្ងាប់វែងយល់ មុខមាសនិមល
សោយទុក្ខផង ឥឡូវអាក័ព្ធ ទឹងស្លាប់នេះម្តង
ពុំបានសូនត្រង មាសមិតពុំងា ៗ ចស្រណោះណាស់
តៀតីព្រែងចាស់ ផ្តល់ផ្តួចជន្ទា គិតតែកូនពៅ
នាងនៅកំព្រា អាសូរក្តាត់ណា សសោកពុំគៀន ៗ
ចអញទឹងស្លាប់ ទុកតែសាសប្ប័ ចរាទជួសប្រាន
ពាក្យនេះឪពុក សង់ទុកជាស្ពាន ឲ្យកូនទៅបាន
សុខសាន្តពជា ៗ កូនឡើយសម្បត្តិ នូវស្នេត្រធត្រ
ឪពុកឲ្យបា ពិក័ត្រសូនត្រង រាជវងនានា
កូនឡើយត្រែងរា ខុសខាតគ្គាំគ្គង ៗ ទោះទោសស្រាលធ្ងន់
បាកុំប្រកាន់ ប្រណីរាផង កុំអាលខិងខំ
រាយដំធាក់ថង ផ្ទើដោយគន្ធង ប្បាប់ចាស់ទើបជា ៗ
មួយបើរាទាំ ពាក្យពេជន៍ក្តីគ្តាំ មកទូលកុំបា

សួននៅកន្ដើយ ព្រងើយសោះសា ចូរពិចារណា

ដោះទុក្ខវាផង ៗ កូនជាក្សត្រា ប្រដូចគង្គា

ត្រជាក់កន្ទុង ពស្ដ្រដូចមេឃា គណនាមើលហោង

ផ្ញើជនជាតិផង នូវមហាក្សត្រា ៗ ហើយស្ដេចផ្ដាំពី

ក្សត្រ ៤ ជាគី លៀងនៅវេឡា សឹងមានគុណធ្ងន់

លើសលន់ក្ដាត់ណា ឲ្យយសសក្ខិតា ឲ្យថែប្អូនក្រៃ ៗ

ឪពុកក្សែពៅ នរណាទឹងនៅ បម្រុងឲ្យនៃ

ទោះសុវណ្ណា ពុំងាប្ងាថ្ងៃ ខុសគ្គងព្រះទ័យ

ម្ដេច ៗ ក្ដីណា ៗ សុំជេរប្រដៅ សិទ្រិមអត់ទោ

អាសូរដេយ្យា ឪពុកទឹងផ្ញើ នាងលើសួនក្សា

តាមតែករុណា អាណិតនាងហោង ៗ ហៃសុវណ្ណា

ចំពោះក្សបីតា ផ្ដែផ្ដាំនេះម្ដង នាងនៅឯក្រោយ

កុំឲ្យព្រោយផង កុំធ្វើឲ្យធ្គង ព្រះទ័យកូមី ៗ

កាលលោកខ្វាល់ណាស់ កុំនាងអាងចាស់ តតបសំដី

ទទួបទទិង ខេខិងខ្ញីខ្ញែ ឈ្មោះព្រះបក្រី

ពុំគត់ទេយ្យា ៗ នាងទូលតែគួរ ល្អាតល្អមសម្រួល

ដោះដោយប្រាជ្ញា កុំឲ្យស្ដេចខ្វាស អស់រាស្ដ្រប្រជា

[illegible]នឹងនិទ្រា　　តាំងនាងឯងផង ៗ　　មួយកុំខំខាន
ឈ្មោះឈ្មុសប្រចាន់　　ព្រះបាទព្រះបង　　ទោះសុំស្រីគ្គា
បរិតាក់ក្ដីហោង　　ស្ដែងស្ដេចចែងចង　　មេត្រីស្នេហា ៗ
គួរមាសបន្ទូល　　អាចអនុកូល　　ព្រមព្រះរាជា
ស្ងួនត្រង់រួមរក់　　ពិភ័ក្ត្ររក្សា　　តាមព្រះចិន្តា
ក្សត្រក្សានប្បះប្បង ៗ　　កូនខ្ញើយមួយបើ　　កិច្ចការសារពើ
ជូនស្រាលក្ដីហោង　　ល្ហុមបាត់ល្ហុមចែង　　ថ្វាថ្លែងសាសង
កុំកូនស្ងួនត្រង់　　បណ្ដាយឲ្យរ៉ា ៗ　　ទោះតាំងគ្រឿងស្រង់
ក្រពះប្វូងចន្ទ　　សុគន្ធមាលា .　　ព្រះសិទ្ធីរស
ព្រះព័សក្ខសា　　សុភារ៍បាទា　　សារពើរគ្រឿងផង ៗ
មេមើលបន្ទូ　　កុំឲ្យតែគេ　　តាំងឡាយនោះហោង
ប្ដូរទើបព្រះបាទ　　ននាចប្រះប្បង　　សព្វព្រះទ័យផង
កូនកែវកំព្រា ៗ　　ស្ដេចសោកសែនថ្វី　　ឈ្មៀតផ្ដាំពោធិ៍
សត្វស្នួរសោកា　　ហៃព្រះជនគោ　　សោផ្ដាខត្តឡា
ចាំពាក្យជីតា　　ផ្ដែផ្ដាំនេះម្ដង ៗ　　ឧថៃនេះនឹង
ប្រាស់មាសព្រលឹង　　មិនមានទូវផង　　បាទូវរក្សា
បាឯងហោង　　កុំឲ្យមានហ្មង　　មន្ទិលទៀយណា ៗ

ខុបាបព្រេងជាតិ តែងតាមបង់ឃ្លាត និរាសពីគ្នា
ជម្ងឺរឹងខ្លាំង ទន់ទាំងកាយា ហើយចំផ្តាំថា
បណ្តាលថ្ងើមថ្ងៃ ៗ ខុអញព្រាស់ទៅ ព្រាស់នេះហើយហៅ
ព្រាស់ទាំងអាឡៃ ពីនេះទៅហើយ កូនអើយរាប់ថ្ងៃ
រាប់ខែឆ្នាំនៃ មិញមិនយល់ឡើយ ៗ ចិត្តាប់ចរចា
ធ្លាប់វែងថ្នមបា ថៃថើបលំហើយ ទោះទុក្ខប៉ុន្មាន
ស្រាកស្រានស្រាលស្បើយ នេះម្តងម្តេចឡើយ និរាសបាត់បង់ ៗ
កាលបាទៅឆ្ងាយ តានៅឯអាយ សោកសង្រែងរង់
នេះម្តងតាក្យែ ប្រែឡែបាត់បង់ សំស្ងួនទឹងរង់
មើលផ្លូវពុំយល់ ៗ ស្តេចផ្តាំពោធិ៍ បុត្រាបុត្រី
ធម្មិកសោតសល់ នូវនាងសុច្ចា សោភាទិមល
នូវព្រះទសពល សនុរាជា ៗ កែវកេសរ្ទី
ប្រសើរស្រស់ស្រី ទាំង ៤ អង្គា ថ្កើងផុតបុរស
ខ្ពង់ខ្ពស់ក្តាត់ណា ហេតុមានមេត្តា ទើបសង្វាតមក ៗ
ខុតឡូវមិញ បង់ដោះដៃចេញ បោលស្ងួនពន្ទូក
បំណាច់ស្នែងស្នេះ ក្រឡាស់ក្រឡក ម្តេចឡើយបង់មក
ប្រែព្រាស់ឃ្លាតឃ្លា ៗ ប្អូននៅចុះហោង កម្មវិបាកបង់

បងអ្នកនឹងលា លាហើយសូមផ្ញើ ខ្ញាបលើអ្នកណា
លើកសព្វសង្ខារ តាមច្បាប់ក្សត្រផង ៗ ឪអាសូរក្ដាត់
នើយហាតពុំគិត ហេតុមានបំណង មកនឹងផ្ដេកផ្ដិត
ឲ្យស្និតនឹងបង បងមកហើយហោង សំអ្នកអាឡៃ ៗ
ឲរសរូបា មូលមួយនឹងគ្នា គួរក្បានព្រះទ័យ
នេះម្ដងសឹងទុក្ខ ឥតសុខឡើយនៃ បង់ជីវិតក្សៃ
ថ្ងៃនេះហើយណា ៗ ប្រាំពីរព្រះអង្គ ស្ដាប់ក្សត្រយក្ខទ្រង់
បណ្ដាំប្នោះណា ក្ដៅក្ដាត់អស់ថ្ងើម ដង្ហើមទេយព្រ
ឈឺឈ្លួលឈៀបផ្សា អួលអន់ពេកក្រៃ ៗ ឯអង្គព្រះបាទ
ពៀបពន់សល់ខ្នាត ក្រៃលែងវិសែ បងអាពៅ
កាយានោះនៃ តេជោធាតុក្សៃ សូន្យសោះហោងណា ៗ
ពុំអាចដំកល់ នាទីនុបទល់ ព្រះផនផា
សោយវិលាល័យ ក្សិនក្សៃជន្មា រំពេចនោះណា
លើបន្ទំទ ៗ ក្សប្រាំពីរអង្គ ស្ដេចសោយសោកទ្រង់
កន្សែងសែនថ្មី ព្រះស្នំស្រិគ្ធា បរិពារនារី
នូវមុខមន្ត្រី ទួញយំរំពង ៗ ស្ដេចសោយសោកសល់
ហើយខំដំកល់ ព្រះស្មារតីហោង រុះរៀបប្រញាប់

សព្វប្រដាប់ផង ព្រះស្ថានឥតហ្មង ដាងនៅវេចនា ៗ
គន់ទៅឯក្នាស ធ្លាក់ខ្មៅដាំរាស ត្បូងធ្ងះពណិគ្នា
ពិទូទឹកវិល នៃបនិលមុក្តា វៃមនមាសសោភា
ត្រដួបដោមដុង ៗ រុងរឿងឆ្អិនឆ្អៅ សន្ធោសន្ធៅ
ក្ដីផ្ទុកយល់យង់ តាំងស្វេត្រឆត្រ រាជវត្តឆត្រទង់
ពាសពេញនាគុង សឹងហុនភាព ៗ រៀបរួចស្រេចស្រាប់
សព្វគ្រប់ប្រដាប់ ហើយព្រះរាជា នឹងនាំសពនៃ
ដាក់ឮព្រាងព្រា សាទមេរុសុវណ្ណា ប្រញាប់ហើយហោង ៗ
ឲ្យយកកងរថ ដាំសឹងមរកដ ល្អក្រៃកន្ទង
នាំទបញ្ចប្រាសាទ មាសស្អាតឥតហ្មង កង់ប្រាំបីហោង
ចរន្ទាលនាគា ៗ ទៀនត្បូងយំយាម យុគ្គិតព្រាហ្មណ៍
ចាចាស់ព្រឹទ្ធា កាន់ទង់ព្រលឹង ហើយនឹងយាមស្វា
ឆ្នាំងបាយសុវណ្ណា ចងកយួរទៅ ៗ អ្នកក្ដុកតាំង ៤
ធំ ៗ មាំមួន ដួតសរសឹងនៅ ដោយមុំសរសេរ
ដើងចកមាសខ្មៅ ភ្លេងក្លាតឯក្រៅ ទ្រហឹងអឹងកង ៗ
ប្រទីបផ្កាលា ទៀនធូបក៏ផ្កា ព្រោងប្រុសក្ដាត់ហោង
កងារបិតបាំង នូវកំងននចង ជុំជិតមេរុហោង

ពុំខ្វះឡើយណា ៗ មានទាំងរូបភាព សុតសឹងសត្វស្លាប
នៅអាកាសព្រ ពពកផាយផាត់ ប្រវាត់តព
ភិជានក្ងាយជា ហង្សហើរពាំក្ញី ៗ ក្បិនលើកសព្វថ្ងៃ
ដំកល់ដាក់ញ្ញ រាជរថមាសខ្ចី ភ្លឺផ្លេកលលាម
ទីមទាមរាជសី រូបរស៉ីវិសេ ស្មើស្មុះសោះសា ៗ
វៃគ្រគ្រុឌកំពាន់ ប្រឹងប្រាណកកាន់ លើកលុតបាទា
ខំខាំមាត់មួន ក្រទួនអង្គា ក្រៃឡោតនេត្រា
ហើយហាក់ទឹងចិង ៗ រូបកំពាន់ឈរ វៃខងខំឆើយង
សំឡក់សំឡៀង ស្ងួយស្ងុមស្ទើរស្ទា ក្រទាទ្រមឹង
ធ្ងុកធ្ងុះនៃបទឹង កំពាន់គ្រុឌា ៗ រូបទេព្វអប្សរ
នៃបទឹងគិន្នរ នូវរូបទេព្តា កកាន់បុប្ធុំ
ក្រពុំបុប្ផា ទ្រង់គ្រឿងសុវណ្ណា ល្អ ៗ ប្រពៃ ៗ
ប្រាំបួនជាន់ជាក់ រាយរៀងពល់ថ្នាក់ វៃគ្រភជរតថ្ងៃ
សឹងកាន់ក្ញីផ្កា មាលាដោយដៃ ល្អលើសវិសេ
នូវបេះបរបា ៗ ឯវរក្សត្រី ប្រសើរស្រស់ស្រី
នាងសុវណ្ណា នោះនាងទ្រង់ប្រាយ លាចថ្វាយបិតា
ព្រះពជបុត្រា ទ្រង់ស្បូវក្លាំងផង ៗ បរិពារប្រុសស្រី

ហៃក្សត្រធិបតី វីរអឹងគង មានក្មេងមហាស្រព
គ្រាន់គ្រប់ជាម្ដង ពុំលង់ឡើយហោង រំកិលឃ្មាតឃ្មា ៗ
កាំភ្លើងបាញ់គ្រាំ បម្រៀងរបាំ ភ្លេងសព្វគាសា
សន្ធឹកសន្ធប់ ញាំញាប់មហិមា ស្ទើរធ្លាយកស្បា
កក្រើកខ្ទាខ្ទរ ៗ ហើយបញ្ឈប់នា កណ្ដាលមាគា
ទើបក្សត្រទ្រង់ធម៌ ស្ដេចឱ្យជាទាន សឹងមានគ្រប់ពណ៌
ស្រើបស្រួលខ្សៀវខ្សា មកយកទិព្វទាន ៗ រឯករអិក
គគុកគគិក អរឯងគ្រប់ប្រាន លុះប្រាំពីរថ្ងៃ
ហើយនៃទើបបាន ដល់ប្រាសាទឋាន មែនមានរចនា ៗ
ដំកល់ព្រះសព ហើយលេងមហាស្រព សព្វទិន្នទិព
ពស្ត្រផងក្នុងក្រៅ លំនៅនា ៗ មូលមកត្រៀបត្រា
មើលមិនឆ្អែតឆ្អន់ ៗ មានសុគន្ធិក នៅកាលបូព្រឹក
សឹងទ្រព្យទិព្វគន់ កែវកង់ប្រាក់មាស នឹកាសលើសលន់
សាចបាចច្រើនពន់ ពុំដាច់ឡើយណា ៗ ដណ្ដើមខ្វលខ្វៅ
ពកូនពពៅ ប្រពានពូនពា បង្អៀតតាន់តាប់
ខ្ទាន់ខ្ទប់លើគ្នា ខឹងខំប្រព ដណ្ដើមបង់បាន ៗ
មើលមេគ្រិះហា កញ្ច្រូបរន្ទា សព្វប្រដាប់មាន

សម្រែកសក្តិសម　បួរឈ្មុំយោនយាន　ក្ងីផ្ទុកព្រាលហាន
អាកាសក្យោមា ៗ　ព្រះពោធិវង្ស　ដិះគ្រុធស្តេចទ្រង់
ពីទិសបូព៌ា　ព្រះវរជិនី　ក្សត្រីសោភា
ទ្រង់យន្តទេព្តា　ដិះលើរាជហង្ស ៗ　ពីទក្សិនស្មោះ
ព្រះដៃជេតនោះ　ស្តែងស្តេចទ្រើសទ្រង់　ពីទិសបច្ចិមា
ទេព្តាសោតគន់　គុជ្ជនរូបរង់　រៀនរិនល្អក្រៃ ៗ
ធម្មិកពជា　នូវនាងសច្ចា　សន្ទុដៀសដៃ
នាងកេសនី　ក្សត្រីប៉ាថ្លៃ　ទើបទិមម្នាមៃ
ពីទិសឧតរ ៗ　លុះបានពិលា　អុបអស់រន្ទា
កាំជ្រួចខ្នុខ្នូរ　ស្តេចប្រាំពីរអង្គ　ត្រសងកែករ
ស្តែងស្តេចចេញចរ　ដម្រង់ទៅទ្វារ ៗ　ហើយចូលដល់បាន
ឆ្លួលឆេះព្រះស្ពាន　ផ្សែងផ្សប់មេឃា　ពលរិនឆេះគួច
គ្រលួចក្យោមា　សន្ធោឯកា　កាសកាលនោះនៃ ៗ
ឆេះព្រះសពសុះ　ស្រាប់ស្រេចកាលនោះ　ព្រឹកឡើងក្សត្រថ្ងៃ
រើសធាតុយក្យា　បីតាដៀសដៃ　ស្រេចការកាលថ្ងៃ
នោះឯងហោងណា ៗ　កាលនោះព្រះបាទ　ឲ្យសង់ប្រាសាទ
មាសមៃថ្ងៃថ្លា　ដម្កល់ព្រះធាតុ　ព្រះបាទបីតា

តែងទៅវន្ទា  បង្គំមួង ។ ។  ក្សត្រព្រាំពីរអង្គ
បន្ទោសោកបង់  ក្រែមក្រានឥតហ្មង  ដៃដេតកជា
ថ្ងៃថ្វាប្រះប្រូង  ស្តេចសោយរាជ្យស្នង  ព្រះវរបិតា ។
រាស្ត្រមុខមន្ត្រី  សុខសានសួស្តី  ដោយបុណ្យក្សត្រា
ហើយព្រះបំណាង  សង់គុណវិទ្យា នូវ ៤ អង្គា  កំលៀងនោះហោង ។
ឲ្យសង់ប្រាសាទ  ធំ៥ ស្អាងស្អាត  ល្អក្រៃកន្ទុង
បួននោះភូមិ  ឲ្យកំលៀងហោង  ស្តេចគង់ឥតហ្មង
ទាំង ៤ ក្សត្រា ។  មួយនោះល្អក្រៃ  សឹងមាសប្រពៃ
ឲ្យនាងវិទ្យា  ហើយឲ្យសសក្តិ  អានាក់ថ្ងៃថា
ទ្រព្យធនគណនា  រិសរាប់ពុំបាន ។  កំលៀងវិទ្យា
ថ្កល់ថ្កើងសក្ខិតា  ទីទៃគ្រប់ប្រាន  បរិពារប្រុសស្រី
ផងក្តីសិងមាន  គ្រៀបត្រាក្នុងស្ថាន  ប្រាសាទនោះណា ។
ពុំឲ្យទើសទាល់  មន្ទិលពិតាល់  អន់អាក់ចិន្តា
សុខសលលោះលាយ  សប្បាយទេយ្យា  ថ្កើងពង្សវង្សា
សន្តានទៅផង ។  លង់លុះតិចទៅ  ព្រះបីតានៅ
ជិនីប្យស់ប្យង  ទាំង ៤ ព្រះអង្គ  គួរគង់ឥតហ្មង
ព្រះចិន្តាផង  ចង់ទ្រង់សិក្សា ។  ក្បៀនស្តេចត្រេចទៅ

ផ្ដានបុត្រចោមចៅ ទាំងពីរអគ្គា នៅពោធិសត្វ
បុរសរតថ្ងៃថ្ងា បន្ទូលលោមលា នូវពាក្យមេត្រី ៗ
ស្ងួនើយអញ្ចុ ពុកម្ដាយលាពៅ មាសមិត្តទាំងបី
ទៅសាងសីលភាព ស្និទ្ធស្នាច់ទូរទី ឃ្វាឃ្វាតអំពី
ពៅពុំនែបទិត ៗ កូនើយសម្បត្តិ នូវស្វេត្រធត្រ
ផ្ទៃក្រោមក្រមក្រិត្យ ផ្ទេផ្ទុឲ្យបា ពំណាំស្នែស្និត
គ្រប់គ្រងតាមចិត្ត ចាបុត្រចើមថ្ងៃ ៗ ក្សត្របីអគ្គា
ស្ដាប់ស្ដេចលោមលា នឹងចរឃ្វាឃ្វៃ ទៅសាងសីលា
នៅនាព្រឹក្សព្រៃ ព្រមព្រះហឫទ័យ ឲ្យស្ដេចចេញចរ ៗ
ក្សិណក្សត្រថ្ងៃថ្ងា ប្រជាប់អាត្មា ទាំង ៤ បវរ
ស្រេចស្ដេចលះលោក ចេញចាកព្រះនគរ ដល់ព្រឹក្សាករ
ស្ងប់ស្ងាត់អង្វា ៗ ស្ថានមួយកបកល់ ទីទួលថ្នាក់ថ្នល់
មែនមានគោហា ពីបុរាណនាយ សប្បាយក្ដាត់ណា
ជុំផលព្រឹក្សា អាណែកច្រើនក្រៃ ៗ ហើយមាននាទី
ស្រះបោក្ខរណី គួរចតអាស្រ័យ ទឹកថ្លាត្រួបង់
កំពង់នោះនៃ ផ្កាលស្អាតប្រពៃ ឆ្មកឆ្មរត្បូងក្បាច់ ៗ
សំគួរជាស្ថាន អ្នកសាងសីលទាន ទើបទាំង ៤ ស្ដេច

ស្រែចបរបួលគន់ ទ្រន់ផ្ដីសរំពេច ជាតាបសស្រេច
ទាំង ៤ អង្គ ៗ ឥសីសីលសាទ សង្វេគសង្វាត
បំរើនគារវនា ៗ សប្បាហ៍អស់អញ បំពេញធម្មា
សព្វទិន្នទេក់ ពុំដាច់ឡើយវៃ ៗ វិរាជដេយ្យា
នាងបានបួសជា តាបសសីថ្ងៃ បំរើលំអុត
ផ្គន់ផ្គត់ទីទៃ ហើយតែងទៅព្រៃ បេះផលទាំងឡាយ ៗ
ផ្លែឈើមើមឈើ ផលផងសារពើ រើសរកមកថ្វាយ
តាបសពីរពង្ស ស្ដេចគង់ស្វាធ្យាយ សង្វាតខ្វល់ខ្វាយ
ស៊ូន៍ស្វាច់នៅហោង ៗ ទឹកស្រង់ទឹកផាន់ ស៊ីងជាកំណាន់
បំរើតគហ្វង ឯកាជ្យបុត្រា ថ្ងៃថ្វាឥតគ្គង
នូវព្រះបរ្យះបរ្យង ពូជពង្សពុទ្ធា ៗ នូវនាងក្សត្រី
ប្រសើរស្រស់ស្រី នាងសុវណ្ណា ស្ដេចតែងទៅថ្វាយ
កកាយវន្ទា ទានធូបក្កា ថ្វាយជាប្រក្រតី ៗ
ស្ដេចសោយពង្សស្កល់ ឯកឥតអម្ពល់ នគរទាំងបី
ឥតមានភ័យ្យា ពេគាព្យាធី ក្សេមក្សានសួស្ដី
លង់តិចឡើយណា ៗ ព្រះពោធិសត្វ មហាបុរសគេ
បំរើនជន្ទូវស្យា ល្អុល្អះស្រៀបស្រស់ សោឡសឆ្នាំណា

ពីព្រះរាជា　　រម្ភក់ស្ងួនគ្រង ៗ　　ទ្រង់ធោមធាយា
ពាលពេញរូបា　　មើលមិនមានទគ្គង　　ហាក់អង្គឥន្ទ្រា
សោភាឥតហ្មង　　ឥតនរអ្នកផង　　នាទំងស្មើរបាន ៗ
កាលនោះមាតា　　ព្រួយព្រះចិន្តា　　ទឹងបុត្រកល្យាណ
ឥតអគ្គម្ហេសី　　ទេពីរួមស្មាន　　គួរគូផ្ទឹមបាន
នូវទុរស្រួ ៗ　　ក្បិនកក្រើកដល់　　អាស្នាមណ្ឌល
សម្តេចឥន្ទ្រា　　ស្តេចបើកទិព្វចក្ខុ　　ដឹងជាក់ដោយនា
នាងសុវណ្ណា　　ព្រួយព្រះហឫទ័យ ៗ　　ហើយទ្រង់ចិន្តា
ទិគ្គនរណា　　ក្បិនជាកន្យ　　ក្បិនដឹងដោយនា
ប្រាជ្ញាទិព្វថ្លៃ　　យល់នាងមួយនៃ　　ប្រសើរសោភា ៗ
រូបពង់កល្យាណ　　គឺគូបុរាណ　　ព្រះពង្សពុទ្ធា
នាមនាងកេស្សរត　　ល្អក្តាត់ថ្លៃថ្លា　　នាងស្ថិតនូវនា
ចត្តរកភោ ៗ　　ហើយព្រះឥន្ទ្រា　　ចុះចាកសួគ៌ា
ត្រេចត្រង់ទិសទ　　ដដល់ហើយណា　　ឥន្ទ្រាលក្កា
ពិសេសសេដ្ឋា　　ឃើញនាងធិតា ៗ　　ពនាងនាថហោះ
សំដៅចំពោះ　　សឹងហុនភារ　　ដល់បរបូលថ្នាត់
ថ្វាយក្សត្រថ្លៃថ្លា　　ឲ្យជាពន្ធិតា　　ព្រះពង្សពោធី ៗ

ផ្តាំឲ្យអភិសេក ដំកល់ជាឯក លើសៅដៃស្រី
ស្រេចទើបសក្កោ ទេវាធិបត្តី ស្តេចហោះទៅទី
សុខសួគ៌ាលៃ ៗ នាងសុវណ្ណា បានកូនប្រុសា
ពេញព្រះហឫទ័យ ទាំងព្រះបីតា ក្សត្រាជៀសដៃ
ទ្រង់មេត្តាក្រៃ ទឹងនាងធិតា ៗ ស្តេចឲ្យរន្តាប់
ការផងប្រញាប់ ពុំលង់ឡើយណា ទើបអភិសេក
បុត្រឯកអគ្គា នូវនាងជេយ្យា កេស្សរថ្វាថ្ងៃ ៗ
បន្ទៃសម្បត្តិ ប្រជារាស្ត្រត ឲ្យព្រះបោមត្រៃ
ក៏បណ្ឌិត ព្រាហ្មព្រឹទ្ធិសាសវៃស អរអើងឲ្យដៃ
ព្រះពង្សពុទ្ធា ៗ ឯព្រះពោធី បានពង្សទេពី
ទ្រង់លក្ខិណា ព្រឹព្រោងព្រះស្រី ប្រិមប្រិយ៍ថ្ងៃថ្វា
ដូចបូរប្រន្ទា ត្រចះចែងចាំង ៗ នីនូវពពក
តិបត្តប្មួយមក ពាសពាមទបាំង ក្ចិផ្ទុកសន្ទៅ
ផ្អិនផ្អៅទ្ធួរទាំង កូមិកតរៀងកំង សីសាយសោះសា ៗ
ព្រះពោធិសត្វ ស្តែងស្តេចប្រតិព័ទ្ធ រួមរក់ស្នេហា
មិនដែលឲ្យអាក់ ថ្នាំងថ្នាក់ចិន្តា ស្ងួនគ្រងរក្សា
មិនឲ្យមានហ្មង ៗ ឯអស់ក្សត្រា សព្វប្រទេសណា

នាំបុត្រមកផង ពីរយអង្គា ឆាយាឥតគ្គង
ទន់ភ្លន់ភន្លង មកថ្វាយរាជា ។ ស្ដេចអរស្រាកស្រួល
ព្រិព្រមទទួល អស់អង្គធីតា ល្អ ៗ ស្រៀបស្រាប់
អណ្ដាប់ដោយគ្នា កៀមក្រានសុខសា បាយបុណ្យពោធី ។
ស្ដេចសោយរាជ្យស្កល់ រាស្ដ្រតសុកល ឥតមានព្យាធី
ក្សត្រីវលក្ខ ព្រះអគ្គមហេសី នាងទ្រង់គភិខ្ចី
ពិសុទ្ធសោភា ។ ឯព្រះភូមី ស្ដេចមានប្រណី
ស្ងួនគ្រងស្នេហា មិនឲ្យខ្វាកខ្វល់ ពិភាលចិន្ដា
មានអ្នករក្សា ថ្នាក់ថ្នមបីទ្រ ។ ឲ្យរើសមារយាទ
រើសរូបស្អាត ៗ ក្រមុំល្អ ៗ សន្ដានថ្ងៃ ៗ
នោះនៃទើបយក ថែទាំបីទ្រ សព្វថ្ងៃប្រក្រតី ។
អន្ដាប់នោះណា ទើបអស់ធីតា បន្ទាប់ក្សត្រី
សឹងទ្រង់គភិបុត្រ ពិសុទ្ធប្រិមប្រិយ៍ កៅសិបពីរខ្ចី
ថែមទៀតផងណា ។ ទាំងវរក្សត្រី ត្រូវកៅសិបបី
ស្ដេចទ្រង់មេត្ដា ស្ងួនគ្រងរៀមរក់ ពិភាគរក្សា
សព្វទិនទិវា មិនឲ្យមានហ្មង ។ លុះទសមាសា
កេស្សរតដេយ្យា ឯអង្គប្យះប្យង ប្រសូតិរាជបុត្រ

ពិសុទ្ធឥតហ្មង ល្អល្អះកន្ទុង ព្រានប្រុសសោភា ៗ
ព្រះពោធិសត្វ សព្វព្រះទ័យក្តាត់ ទឹងបុត្តពាំងា
ហើយថ្វាយនាម្ករ បវរសេដ្ឋា ស្តេចឲ្យហៅថា
សិន្ធរតកុមារ ៗ ឲ្យរើសមេនុំ ស្អាងស្អាតសក្តិសំ
រក្សាព្យាបាល ឲ្យធាត់មិនស្គម ល្មាក់ល្មមរូប៉ា
បំបៅកុមារ សព្វទិនទិវ ៗ របាំបម្រៀង
បំពេរប្រូបប្រៀង បន្ទុងបុត្រា ទោះនាងបន្ទាប់
អន្ទាប់នោះណា ទៀងទសមាសា បរិបូរហើយហោង ៗ
ប្រសូតិជាក្រោយ អន្ទាប់អន្ទោយ គ្រប់អង្គជាម្ទង
ទាំងកៅសិបផ្កាយ ឆោមឆាយកន្ទុង សឹងប្រុសឥតហ្មង
ល្អ ៗ ដូចគ្នា ៗ ព្រះពោធិវង្ស អរក្រៃសឹងទ្រង់
ព្រះក្សានករុណា ឲ្យមេនុំនៅ បំបៅបុត្រា
គ្រប់អង្គនោះណា ពុំខ្វាស់ឡើយនែ ៗ ដៃដេតកាជា
នាងសុវណ្ណា សព្វព្រះហឫទ័យ ទឹងព្រះជនគោ
សេដ្ឋាថ្វាថ្ងៃ រក្សាសព្វថ្ងៃ ពិតពុំមានហ្មង ៗ
លង់លុះទៅណា បំរើនផនស្បា បុត្ររតប្រះប្រង
ឆោមឆាយកាយា បុកពាល្គាយល្គង មើលមិនមានខ្គង

អស់អង្គរូបា ៗ កាលនោះព្រះបាទ ជៃជេតននាថ
នាងសុវណ្ណា ក្នុកព្រះចរិត គុនគិតថៃថា
ទុកអនិច្ចា សព្វសត្វសម្លាយ ៗ រូបហើយកុំជឹង
ជំពាក់នៅទឹង កិលេសទាំងឡាយ គួរប្រែគួរប្រាស
លាកលះឲ្យឆ្ងាយ កុំគិតកុំស្តាយ នៃបនិតទឹងវ៉ ៗ
គួរតែសង្វាត អស់អញស្ទឹងស្នាត បំរើនភាវនា
តាមព្រះពុទ្ធទុស្ស ឲ្យប្រោសសព្វា គគៀកាន់មហា
នគរទិញ្ញន ៗ ស្រេចទ្រង់ចិន្តា យល់ក្តីអាណា
គតកាលក្សត្រក្សាន ស្តេចបើកព្រះស្ទូរ បន្ទូលទៅថ្កាន
ទីងបុត្រកល្យាណ ទាំងពីរអគ្គា ៗ ហៃស្ងួនត្រកាល
សត្វសាប់សង្ស្យ ស្តាប់ពាក្យបីតា យើងពីនេះសំ
ចាកបំបែងបា ទៅសាងសិលា លែងលះទ្វរទំ ៗ
ស្ងួនឡើយអ្នកនៅ យើងសូមលាទៅ ទាំងពីរពិសី
បានៅឯក្រោយ កុំភ្លោយសេបក្តី ពស្តុមុខមន្ត្រី
ពិភាគរក្សា ៗ ហើយព្រះមហាក្សត្រ ផ្តាំទាំងវរត
ទន្តោថៃថ្វា អប់ភាចពាក្យពេជ ស្រាប់ស្រេចហើយណា
ឯកជបុត្រា នៅភជបុត្រី ៗ នូវអស់កុមារ

ត្រកូលត្រកាល សឹងឱនអគ្គី ក់ទវិវន្ទា
ក្សត្រាធិបតី អាឡៃឥតបី នូវផ្ទឹមឧបមា ៗ
កាលនោះព្រះអគ្គ ផ្ដាំស្រេចពុំលង់ ពីព្រះរាជា
ប្រុងប្រៀបប្រដាប់ សម្រាប់អាត្មា ហើយស្ដេចលេលា
ស្ដេចទៅជាមួន ៗ ពុំយកយោធា ពលពាលអាសា
មួយមកជិតផង តែពីរព្រះអគ្គ ត្រេចត្រង់ដោយផង
ដល់អាស្រមផង យល់ប្អូនក្សត្រា ៗ ស្ដេចដល់ស្ដេចថ្វាយ
បង្គំកកាយ ក្សត្រ ៤ អង្គា ហើយទូលសូមផ្នួស
ទឹងបួសជាតិជា តាបសព្រះមហា ឥសីសីលថ្ងៃ ៗ
បួស្សី ៤ អង្គ ស្ដាប់ស្ដេចពីពន្យ ហើយត្រេកអរក្រៃ
បំបួសរំពេច ស្រាប់ស្រេចហើយនៃ បរិបូរត្រៃពៃ
ជាតាបសព្រ ៗ កាលនោះពុំលង់ ព្រះឥន្ទស្ដេចទ្រង់
ព្រះទិព្វចក្ខា ប្រើពិស្ណុកាថ្កាន ចាកស្ថានសួគ៌ា
មកធ្វើស្ថានអា ស្រមស្រេចឥតហ្មង ៗ មួយថ្វាយព្រះបាទ
មួយថ្វាយនាងនាថ សុវណ្ណហោង ធ្លាក់ខ្លៅក្សួរក្សាប់
រម្មបទាក់ទង ស្រួលស្រេចឥតធ្លង សឹងសុវណ្ណា ៗ
បួស្សីពីរពន្យ ស្ដេចឡើងទៅគង់ ទីនៃពីគ្នា

ហើយតែងក្រនេវ៍ បំរើនមេត្តា សង្វេគៗនិច្ចា
បំពេញធម៌ថ្ងៃ ៗ ឯសុវណ្ណា នាងតែងយាត្រា
ត្រេបចរចូលព្រៃ បេះផលព្រឹក្សា នានាច្រើនក្រៃ
ប្រក្រតីសព្វថ្ងៃ ថ្វាយ ៥ ភជា ៗ អគ្គឯងបំរើ
កិច្ចការសារពើរ ពុំមានអ្នកណា មួយមកកំដរ
តែផងឯក្កា ទ្រង់ព្រឹទ្ធិសត្តិយា ស្ងប់ស្ងាត់ប្រជុំ ៗ
យើងនៅជំណាល ដំណើរពីកាល ពង្សពុទ្ធឧត្តម
ក្រោយព្រះបីតា លាកលាលះលំ នូវនេះស្តេចពុំ
ផ្សេងផ្សូរឡើយណា ៗ មានព្រះសុវណ្ណី បបួលក្សត្រី
កេស្សរតជាយា ស្តេចទឹងទៅថ្កាន ក្សត្រកក្រានថ្ងៃថ្វា
ប្រាំមួយអគ្គា សាងសីលនោះនៃ ៗ ក្សត្រីក្សត្រា
ព្រមព្រះបិត្តា ទើបព្រះជៀសដៃ នាំអស់រាជបុត្រ
ពិសុទ្ធទើមថ្ងៃ គង់យានមាសមៃ បរចេញយាត្រា ៗ
ជន្ទ្រីត្រៃសាំង ក្ញឹងក្បោះបើកបាំង ជាមួបឆាយា
ត្រសុំត្រសាយ រំកាយវត្ថា ពលពាលត្រៀបត្រា
ខ្ទានខ្ទាប់អឹងកង ៗ ស្តេចទៅលុះបាន ដូចដល់នាស្ថាន
អាស្រមហើយហោង ចុះចាកយានថ្ងៃ ប្រពៃឥតហ្មង

បបួលទៅផ្គង　បង្គំវន្ទា ។　ក្សត្រប្រាំមួយអង្គ
យល់ព្រះពុទ្ធពង្ស　ត្រេកអរមហិមា　ជួមព្រះជនតា
ទុត្តមោទត្តលា　សំណោះបរវា　សួរសព្វសេចក្តី ។
លង់លុះសុរិយា　ទន់ទេហើយណា　ស្តេចវិលវឹងវិញ
គង់លើប្រាសាទ　ស្អាងស្អាតសោភី　ដូចកាលអំពី
មុនមកនោះនៃ ។　ហើយស្តេចតែងទៅ　សួរព្រះចោមចៅ
ជាតសីសៃ　ទុក្ខសោកពុំមាន　ក្សេមក្សាន្តព្រះទ័យ
កេកាលនោះនៃ　ឯនាងវិឡា ។　ដោយវេរាកម្ម
វិបាកបងចាំ　ជិតដោយអាត្មា　ពុំអាចទុបទល់
ដំកល់កាយា　ក្បិនក្បែដន្ទា　កាលនោះឯងហោង ។
ព្រះពោធិសត្វ　ចោមចៅបក្រព័ត　ពន្ទឹលោកផង
ស្តេចមានមេត្តា　ករុណាកន្ទួង　ស្តែងស្តេចទូវសង
គុណនាងវិឡា ។　ឯព្រះជិនី　ជាតាបស្សី
នាងសុវណ្ណា　ជ្រាបអស់សេចក្តី　ពិតពីវិឡា
អាណិតក្តាត់ណា　ថ្វិងថ្វែងពុំបាន ។　នាងទ្រង់ចិន្តា
ហើយនាងភាវនា　រំលឹកសីលទាន　មគ្គផលទាំងនោះ
បំពោះឲ្យបាន　បំរើនកម្មដ្ឋាន　គុណគាប់ប្រពៃ ។

សង់មេនស្រេបស្អាត ល្អល្អះព្រោងព្រាត គួរពាសរចនា
កញ្ចកកញ្ចក ឆ្លុកឆ្លុកក្បាច់ កង្កុកកម្ពុជា
ក្រវិល្ហិកវែង ៗ មានរូបនាគហោះ ពាំកែវផ្លែកផ្លោះ
ស្ទុះស្ទួះពេនពាន រូបទេព្វប្រណម្យ បង្គំកកាន់
បូទុំសោភ័ណ ស្នាទ្រដឹក ៗ ហើយមានមហាស្រព
បរិបូរគ្រាន់គ្រប់ កាំប្របរន្ទា រាជវត្ថុទង់ឆត្រ
រត្នរត់ឆាយា លុះបានពិលា ទើបព្រះពោធិ ៗ
ទ្រង់យន្តទេត្តា ជិះលើគ្រុឌា កកាន់នៅក្រី
ទៀងទើបទាញយន្ត ល្វាសល្វន់ឥន្ទ្រ លឿនលន់ដល់ទី
សម្តិនាងវិទ្យា ៗ ហាក់ទៀបនឹងអុប ក្បិនធ្វើជាចុង
ថយក្រោយរេក ក្បក្បកវិលវង្ស ស្វាញស្ទុងសោះសា
កែងកោងហត្ថា កំរែកអំពើ ៗ ជួបចូលបីជង
ទន្ទ្រូងផ្អៀងផ្អង ញាក់ញ័របពើ មើលហាក់មនុស្សមាន
វិញ្ញាណពុំស្មើ ជាងបេះគិតធ្វើ បម្លាក់ក្រៃក្រៃ ៗ
ហើយអុចឯឈ្នួន គ្រប់មុំទាំង ៤ ពុំលង់ឡើយនៃ
ក្រលួចដួចដាល ភាលភាលអស់ឮ ឆេះសព្វសត្វថ្ងៃ
រំពេចហោងណា ៗ លុះព្រឹកព្រះបាទ ស្ដេចឲ្យរើសធាតុ

| | | |
|---|---|---|
| នៃនាងវិទ្យា | ឲ្យទានធ្វើបុណ្យ | សង់គុណនោះជា |
| ស្រេចហើយណា | ទើបព្រះប្រុះប្រុង ៗ | ឲ្យនាំធាគុណា |
| ទុកលើប្រាងប្រា | សាទសួគិតឥតហ្មង | មានអ្នករក្សា |
| សព្វទាះហោង | ផ្កាទៀនធូបផង | ព្រោងព្រាតប្រក្រតី ៗ |
| កាលនោះព្រះបាទ | ព្រះបរម្ភនាថ | ពូជពង្សព្រោធី |
| គ្រប់គ្រងយក្សា | នៅនាបុរី | ក្រេមក្សានសួស្តី |
| ពស្ត្រតប្រជា ៗ | នគរដ៏ដៃ | សឹងថ្វាយសួយរី |
| ពុំដាច់ឡើយណា | កាលនោះព្រះបាទ | ននាថថ្ងៃថ្វា |
| ស្ដែងស្ដេចយាត្រា | បរបាកព្រះស្នាន ៗ | ទៅគង់ហោមន្ត |
| ប្រសើរសោភ័ណ | ឆ្នាំពីរទើបបាន | ព្រះពង្សសារពេជ |
| ស្ដែងស្ដេចទៅប្ពាន | នគរពាព | ណាសីស្សរសល់ ៗ |
| ឆ្នាំពីរហើយហោង | ទើបវិលវឹងវង្គ | មូលមកមណ្ឌល |
| សឹងហុនភាព | ថ្ងៃថ្វានិមល | ក្រេមក្សានសុខកល |
| ព្រះអង្គយាត្រា ៗ | លុះបានកំណត់ | ដល់ពីឆ្នាំគត់ |
| ហើយស្ដេចលេលា | ទៅទៀតហើយប | វិលវឹងមកណា |
| កំណត់នូវនា | ប្រាសាទនោះហោង ៗ | អស់អ្នកនគរ |
| ក្រេមក្សានសាទរ | ឥតឯមានហ្មង | ប្រទេសសេស្យា |

គ្រៀបគ្រាអឹងកង ឥតទុក្ខភ័យផង ទាំងបីភាព ៗ
ទោះទ្រព្យធនក្តី អាហារបំណី ចិញ្ចឹមអាត្មា
ពុំព្រួយផ្លួញប្រែ ប្រាក់ខែក្សត្រា ស្តេចប្រទានជា
រង្វាន់ទ្រាប់ផង ៗ ដោយបុណ្យក្រូបាល មែនមានដើមកាល
បុរព្រឹក្សឥតហ្មង ផ្ទុកឃ្លាំងផ្ទុកសំ ពៅពុំអស់ហោង
ប្រឹងក្រៃកន្ទង់ កើតសព្វទេព ៗ ស្តេចសោយរាជ្យស្កល់
នាគ្ទង់មណ្ឌល ឥតមានទុក្ខា កាលនោះរាជបុត្រ
ពិសុទ្ធសោភា បំរើនជនស្បូរ សោឡសឆ្នាំនៃ ៗ
ព្រះពុទ្ធង្កុល ពន្ទុកបន្ទូល ពន្ទឹកពាក្រៃ
ប្រាជ្ញាគឺខ្លួន ជំរនរាំងវៃ ធ្មង់យល់ដល់ញូ
កំណើតសត្វផង ៗ សិង្ហមានទុក្ខា កាលបើរជា
មរមកហើយហោង ពុំដែលដៀសបាក ផ្ទោះផ្ទាករម្មង់
ទៀយជ្រិតបំណង បំណាំកាកាយ ៗ មានកាលទិតនៅ
ប្រពន្ធកូនចៅ មេបាទាំងឡាយ មានកាលព្រាត់ប្រាស់
និរាសចេញឆ្ងាយ មានកាលសប្បាយ ទូវទឹងសម្បត្តិ ៗ
មានកាលធ្លាក់ខ្លួស់ ចាកបោលសក្តិយស ព្យាធិជំកាត់
មានកាលហិនហៃ ក្សិនក្ស័យបង់បាត់ សោះសូន្យស្ងប់ស្ងាត់

ចោលបុត្រភរិយា រូបអើយឥតការ ឥតក្វិមឥតសា
នូវនឹងវេរា គួរគិតទុក្ខ អនិច្ចំអនត្តា
គឺកាមតណ្ហា បំពេញសត្វផង ៗ គួរតែប្រែប្រាស់
ប្រានឲ្យស្រឡះ ឲ្យរួចរម្ងន៍ ពីសោប្រាក់
អន្ទាក់ណែនណាន់ ពុំគួរបិត្តបង់ ផ្ដេកផ្ដិតនឹងវា ៗ
ស្ដេចទ្រង់ព្រះចិន តាទើបកូមិន បន្ទូលត្រាស់ថា ហៃប្អូនត្រកាល
សង្សារស្នេហា ស្ដាប់អាថិវាចា បងនឹងប្រាយប្រាប់ ៗ
ស្ងួនើយបងនឹង លាប្អូនព្រលិង ប្រសើរគួរគាប់
ចេញសាងសីលសាទ ស្ទឹងស្ទាប់ដោយច្បាប់ ព្រះពុទ្ធប្រញាប់
កន្គ្រានេះណា ៗ នាងស្ដាប់ព្រះបង ស្រីស្រស់ឥតធ្គង
លើកករវន្ទា ហើយនាងទូលទៅ ព្រះចៅថាសា
ធុមោទនា នឹងព្រះបាទបោង ៗ បពិតព្រះចៅ
បើស្ដេចនឹងទៅ ខ្ញុំសូមទៅផង បួសបានធ្វើវត្ត
ប្រតិបត្តិឥតធ្គង បំរើព្រះបង ព្រះបាទក្សត្រា ៗ
កាលនោះពោធិ ស្ដេចស្ដាប់ប្អូនស្រី តាមព្រះចិន្ដា
ពិតពុំផ្សព្វផ្សង បង្អង់ឡើយណា ហៅអស់បុត្រា
មូលមកហើយនៃ ៗ បើកបន្ទូលថ្វាត់ ថាហៃសន្មត

បុត្របង្សន៍ថ្មើមថ្ងៃ　នូវអស់ទាំងកូន　ជាប្អូននោះនៃ
បូរស្តាប់សូមៃ　ពាក្យពីបិតា ៗ　ហៃសួនព្រលឹង
យើងពីនេះទឹង　លាកលះបង់ប្មា　ទៅសាងសីលសុទ្ធ
ប្រព្រឹត្តជាតា　បស្សីហើយណា　នាព្រៃទូទី ៗ
សួននៅឯអាយ　រួមរក្សាម្តាយ　គ្រប់គ្រងបុរី
នូវរាស្ត្រប្រជា　ភារនោះក្តី　ចូលមើលប្រណី
ជឹងដោះទុក្ខា ៗ　ឯចៅវីដៃ　នៅកូនមួយគេ
អង្គនោះបូរប្មា　ទៅក្រុងហេមន្ត　សោកណាថ្ងៃថ្លា
នឹងម្តាយអាត្មា　ដោយតូចទៃ ៗ　រិព្រះកៀនថ្កា
អន្តាប់នោះណា　ចូលមាសថ្មើមថ្ងៃ　នាំមាតាប្មា
យាត្រាយ៉ាវៃ　នូវបុត្រមួយគែ　អង្គអាណាជ្ឈា ៗ
ទៅក្រុងបុរី　ពារាណសី　រតរាជសេមា
ឯចៅសន្ធរត　បុត្រក្សត្រសោភា　នូវប្អូនទាំងហា
សិបសោតនៅអាយ ៗ　ឯអស់បុត្រា　ក្រួញក្រាបវន្ទា
ប្រណម្យកកាយ　ទទួលបណ្តាំ　ចងចាំសព្វសាយ
ហើយក្សត្រពន្រាយ　លាអស់ទេព្វី ៗ　ផ្តាំស្រេចពុលង់
នាំនាងឡើងគង់　យានមាសមណី　ពលពាលខ្ទាន់ខ្ទាប់

អឹងអ័បជូលី ហែព្រះពោធី សត្វៈស្ដេចលីលា ។
លុះដល់អាស្រម ពង្សព្រុទ្ធឧត្ដម ចុះចាកយានយា
ត្រាត្រង់នៃឋាន ក្សត្រក្សានព្រះតា បសបុានវន្ទា
ក្រញួក្រាបសិរសី ។ ហើយទូលសុមផ្នួស ព្រះព្រមបំបួស
តាំងពីអង្គទី មួយតាបស្សា មួយតាបស្សី
ស្រគុតឥន្ទ្រិ ក្រមក្រិត្យឥរិយា ។ កាលនោះសោតនៃ
កើតអស់ចារ្យក្រៃ ដោយបុាបីតា ពង្សពោធិញាណ
ត្រើយត្រានលោកា ក្ដៅដល់អាស្នា សម្ដេចកោសី ។
ស្ដេចស្រាប់តែភ្ញាក់ ថាយើនៃនាក់ ណាមានរិទ្ធិ
ក្សិនបើកទិព្វចក្ខុ សម្ដេចកោសី យល់ព្រះពោធិ
នូវនាងជាយា ។ ហើយហោះចុះឋាន និមិត្តជាស្វាន
កុដិកែវរចនា ទន្ទិមពីរក្លោះ ស្ទើរស្ទោះសោភា
ហាក់ស្ថានសួគ៌ា ស្រេចស្រុតមកហោង ។ ក្សិនក្សត្រឡើងគង់
កុដិមួយព្រះអង្គ ឯកឯងឥតហ្មង មួយនោះក្សត្រិ
ទេវីឥតគ្គង គង់ហើយវែងវង់ ចំរើនមេត្តា ។
ហើយស្ដេចតែងទៅ ស្ទឹងស្ទាប់ទិត្យនៅ ស្ថានស្វាតអត្វា
សង្វាតក្រើន ចំរើនភាវនា សព្វទិនទិវា
ពុំលោះឡើយណា ។ ឯនាងកិស្សរត នាងតែងប្រតិបត្តិ
ប្រាំពីរក្សត្រិថ្ងៃ ឈើស្នួនទឹកស្រង់ សឹងផ្គង់សព្វថ្ងៃ

បេះផលព្រឹក្សព្រៃ    នាំយកមកថ្វាយ ៗ    រុក្សត្រៃប្រាំពីរ
ជាព្រះឫស្សី    អស់អញខ្វល់ខ្វាយ    ពុំមានធ្វេសទ្វេរ
ស្រាយស្រែភាយមាយ    ឃើនយូរវែងឆ្ងាយ    ទ្រង់ព្រះជរា ៗ
លុះលែងជាតិថ្វាត់    ប្រាំពីរមហាក្សត្រ    អន្ទាប់ដោយគ្នា
ភិលៀងមន្ត្រី    ភរិយោធា    កំណត់ជរា
រំលាងជនជាតិ ៗ    សឹងទៅកើតស្ថាន    សុខសួគ៌ិកមាន
មាសមៃស្អាងស្អាត    អ្នកណាជឹងបុណ្យ    បុណ្យជូនអង់អាចិ
អ្នកណាប្រមាទ    រូបរង់វេរា ៗ    លុះព្រះត្រេចត្រាស់
សម្មាពុទ្ធស្ស    បន្ទូលទេសនា    សមោធានី
សឹងជាត្តិកា    ដោយញាណភគវា    សន្ទាប់ភិក្ខុផង ៗ
ថាភិក្ខុវេ    ភិក្កើយកុម្ភី    ក្រពើទ្រើសគ្នង
ចិត្តទ្រុស្តប្រមាទ    ឃោឃាតមានហ្មង    ឥឡូវនេះហោង
ចេរិលមកជា ៗ    ទេវទត្តា    គឺនាម្មកោ
ទេវទត្តថេរ    ឥតិបាបំ    នាមំសុរិយា
វែងចារិកា    ទេវទត្តករិយ៍ ៗ    ប្រាំមួយអគ្គា
នារីឫស្សា    ឃោនយកជាត្តុំ    ជាអន្ទេរថី
ទុក្ខីភិយ៍    មោហចិទបាំង    ពំលង់សាសនា ៗ
កេសនីនាម្មោ    ឃោនយកជាគោ    ពេយ្យំសាខា
រនាងឯកអគ្គ    ទ្រង់នាមសទ្ធា    ចេរិលរឹងជា

នាងគោតមី ៗ　　ព្រះបាទសឹងហុន　　យក្ខយកបដិសន្ធ

ចេរិលជាតិ　　ជាព្រះមោគ្គល្លាន　　មែនមានបារមី

ព្រះធម្មិកខ្វី　　ជាព្រះសារីបុត្ត ៗ　　ឯអង្គព្រះបាទ

សន្ធុយកជាតិ　　កំណើតកំណត់　　ជាព្រះអានន្ទ

អាណុបចពង្សពុទ្ធ　　ព្រះនន្ទអនុរុទ្ធ　　ថេរនាមោ ៗ

ដៃដេតកពជា　　ពង្សពុទ្ធបីតា　　ត្រកូលសេដ្ឋា

ចេរិលជាតិជាក់　　សាខេយ្យព្រះផ្សា　　សុមេធម្មោ

បីតាពុទ្ធំ ៗ　　នាងសុវណ្ណា　　ធម្មចេត្តិយា

គឺជាត្តកំ　　ពង្សពុទ្ធមាតា　　ខាយានាមំ

គុណគម្ភីរំ　　អត្ថិធម្មោ ៗ　　នាងកេស្សរតពក់

សារីអង្គអគ្គ　　ម្ហូសីពង្សពោ　　ចេរិលរឹងជា

ពិម្ពារិសោ　　គឺនាម្មតោ　　ពិម្ពាទេវី ៗ

សិន្ធរក្ខបុត្តោ　　ជាក់ជាសេដ្ឋោ　　ចេរិលរឹងខ្វី

ជាព្រះរាហុល　　កពផលកវី　　អង្គកាសិតី

សឹងសាវកោ ៗ　　រីនាងវិឡា　　សត្វបញ្ចក

គុណគម្ភីរេ　　ចេរិលរឹងមក　　យោនយកជាត្រា

ជានាងឯកោ　　សុជ្ជាតាជាតិជាក់ ៗ　　កិលៀងគាំងថី

ចេរិលរឹងខ្វី　　ជាមហាសាវក　　ទិរសពោមចៅ

កៅសិបថ្កាយជាក់　　ជាព្រះសាវក　　សឹងសិស្សសោតា ៗ

ឯបរិពារពល ឯណាមានផល សាងសូមប្រាថ្នា
បេរវិលជួបចូល មកមូលជាតិជា សេសំបរិស្យ
ពុទ្ធបរិសេទ្ធ ៗ ព្រះន្រាយធិបេស ថ្ងៃថ្ងាវិសេស
លើសលើលោកិយ គឺអញ្ញតថា គតជាពុទ្ធេ
គ្រូគ្រប់អស់ឯ មនុស្សស្រពួសត្វផង ៗ នេះគឺនិបាត
បោះបារយជាតិ និទានទំនង ព្រះន្រាយធិបេស
នូវបំប៉ាថោង ដំណើរទំនង ដៃដេតកាជា ៗ
កង្តព្រះបាលី សម្តេចព្រះស្រី សារពេជទេសនា
សម្មោធានី សីងជាតិកា ឥតបក្ខព
និដ្ឋិគោចែងចប់ ៗ ព្រះធម៌ថ្លាថ្ងៃ ដឹងដោយនីសៃ
បើកបន្ទូសព្វ ប្រិងប្រែងពាក្យពេជន៍ កាព្យកិច្ចគ្រាន់គ្រប់
បរិបូរចែងចប់ ថ្ងៃសុក្រទេព ៗ

ចប់តែប៉ុណ្ណេះ

អធិប្បតីបណ្ណាគារ គីម គី ជាអ្នកកែសម្រួល

ការផ្សាយរបស់

បណ្ណាគារ ភារតី

លេខ ៨៨ វិថីអែមេក្រង់ ភ្នំពេញ

ជិតរោងកុន ព្រហ្មបាយ័ន ពីខាងកើតផ្សាល

---

# សេចក្ដីជូនដំណឹង

បណ្ណាគារខ្ញុំបាទ មានទទួលបង់គ្រប់សៀវភៅ មានជាព្រះពុ
រូបថតផ្សេងៗ គឺព្រះរូបព្រះករុណា និងសម្ដេចសង្ឃនាយកជាដើម
សៀវភៅធម៌ សៀវភៅរឿង គ្រឿងសរសេរ សង្ឃដិកា ឆាយា សំ
កំណើត កាតកូនសិស្សនិងសៀវភៅបាកិង-ខ្មែរផ្សេងៗ ជាច្រើន
សូមទ័មន្ត និងអញ្ជើញលោកអ្នកចូលជាវទិញ ដោយមេត្រី
បើទិញដុំ យកទៅលក់ទៀត ខ្ញុំគិតរង្វាន់ជូនយ៉ាងគួរសំ ។

ព.ស. ២៤៩៦ គ.ស. ១៩៥៣

ថ្លៃ ១២រ០០

) រោងពុម្ព ភិក-ភិ ភ្នំពេញ